អង្គការថែទាំសុខភាពគ្រួសារកម្ពុជា រ៉ាក់

# ថ្នាំគ្រាប់ពន្យារកំណើត



## មធ្យោបាយពន្យារកំណើតមានច្រើនជម្រើស

*កម្មវិធីគ្លីនិក*



# មិត្តអ្នកអានជាទីមេត្រី

កូនសៀវភៅនេះ ផ្តល់ព័ត៌មានស្តីអំពី
មធ្យោបាយពន្យារកំណើត ដើម្បីជាជំនួយក្នុងការ
រៀបចំផែនការគ្រួសាររបស់លោក លោកស្រី
ឲ្យបានតាមបំណងប្រាថ្នា និងធ្វើឲ្យសុខភាពមាតា
និងទារកបានល្អប្រពៃ ។

# អ្វីទៅដែលហៅថាថ្នាំគ្រាប់ពន្យារកំណើត ?

គឺជាថ្នាំដែលមានជាតិអរម៉ូន ដូចគ្នាទៅនឹងអរម៉ូនធម្មជាតិក្នុងខ្លួនរបស់ស្ត្រី ប្រើសម្រាប់ការពន្យារកំណើត (រយៈពេលប្រើសមស្របពី ៣–៥ ឆ្នាំ ។

## ថ្នាំគ្រាប់សម្រាប់លេបពន្យារកំណើតមាន ២ ប្រភេទ :

### ១ ‐ ថ្នាំគ្រាប់ ស៊ីអូស៊ី :

ជាបន្ទះថ្នាំមានគ្រាប់ពណ៌លឿងចំនួន២៨គ្រាប់ និងពណ៌ក្រហម៧គ្រាប់ ។ ថ្នាំនេះមានជាតិអរម៉ូន២មុខ គឺអ៊ីស្ត្រូសែន និងប្រូហ្សេស្ទីន ដែលដូចគ្នាទៅនឹងអរម៉ូនធម្មជាតិរបស់ស្ត្រី ។



## ២ ~ ថ្នាំគ្រាប់ ភីអូភី ៖

ជាបន្ទះថ្នាំមាន ២៨គ្រាប់ មានតែ១ពណ៌ មានជាតិប្រូហ្សេស្ទីនមួយមុខ ដែលដូចគ្នាទៅនឹងជាតិអ័រម៉ូនធម្មជាតិរបស់ស្ត្រី ។







# ១ - ថ្នាំគ្រាប់ ស៊ីអូស៊ី

## តើថ្នាំគ្រាប់ ស៊ីអូស៊ី ការពារកំណើតរបៀបដូចម្តេច ?

ជាធម្មតា ការបង្កកំណើតទារកក្នុងផ្ទៃ កើតឡើងដោយការភពប្រសព្វរវាងមេជីវិតឈ្មោល(ដែលមានក្នុងទឹកកាមបុរស ជាមួយនឹងមេជីវិតញី (ដែលបញ្ចេញដោយកន្សោមពងស្ត្រី ។

បន្ទាប់ពីលេបថ្នាំនេះ ជាតិអ័រម៉ូនបានសាយភាយបន្តិចម្តងៗ ចូលក្នុងរាងកាយរបស់ស្ត្រី ធ្វើឲ្យទឹករំអិលមាត់ស្បូនឡើងខាប់ អាចរារាំងការជ្រៀតចូលនៃមេជីវិតឈ្មោលទៅក្នុងស្បូន ។ បន្ថែមពីលើនេះ ជាតិអ័រម៉ូនក៏បានបញ្ឈប់ការខ្ជាក់មេជីវិតញី និងធ្វើឲ្យស្រទាប់ក្នុងរបស់ស្បូនប្រែប្រួល ដែលជាហេតុធ្វើឲ្យការបង្កកំណើតត្រូវបានការពារ ។



## តើថ្នាំគ្រាប់ ស៊ីអូស៊ី មានប្រសិទ្ធិភាពដូចម្តេច ?

ថ្នាំលេបពន្យារកំណើត ស៊ីអូស៊ី១បន្ទះ មានប្រសិទ្ធិភាពអាចការពារការមានផ្ទៃពោះបានភ្លាមៗ រយៈពេល១ខែ ។ បើលេប ស៊ីអូស៊ី ត្រឹមត្រូវ និងទៀងទាត់ ថ្នាំមានប្រសិទ្ធិភាពដល់ទៅ៩៩.៩ ភាគរយ។



## តើថ្នាំគ្រាប់ ស៊ីអូស៊ី មានអត្ថប្រយោជន៍ដូចម្តេចខ្លះ ?

១–មានសុវត្ថិភាព ប្រសិទ្ធិភាពខ្ពស់ងាយប្រើប្រាស់ និង ឆាប់មានកូនវិញ ពេលឈប់ប្រើថ្នាំ ។

២–ផលចំណេញសុខភាពផ្សេងៗទៀតដូចជា :

- បន្ថយការឈឺចាប់ពេលមានរដូវ បន្ថយការធ្លាក់ឈាមរដូវ
- បន្ថយភាពស្លេកស្លាំងរបស់ស្ត្រី និងធ្វើឲ្យរដូវមកទៀងទាត់ ល្អ ។ ក្រៅពីនេះ ក៏បន្ថយការប្រឈមមុខទៅនឹងជំងឺមហារីកស្បូននិងកន្សោមពងផងដែរ

៣–មិនរំខានការរួមរ័ក្ស ។



**សំគាល់**

ថ្នាំគ្រាប់ពន្យារកំណើត ស៊ីអូស៊ី មិនអាចការពារជំងឺកាមរោគ និងជំងឺអេដស៍បានទេ

## តើស្ត្រីណាខ្លះដែលអាចលេបថ្នាំគ្រាប់ ស៊ីអូស៊ី បាន ?

ថ្នាំនេះ អាចប្រើបានចំពោះស្ត្រីគ្រប់រូប បន្ទាប់ពីធ្វើការពិគ្រោះពិភាក្សាជាមួយគ្រូពេទ្យ ហើយគ្មានហេតុផលណាមួយ ដែលហាមមិនឲ្យប្រើ :

- ស្ត្រីដែលត្រូវការមធ្យោបាយពន្យារកំណើតដែលមានប្រសិទ្ធិភាពខ្ពស់
- ស្ត្រីដែលមានការចងចាំក្នុងការលេបថ្នាំបានល្អ
- ស្ត្រីដែលមានឈាមរដូវច្រើន
- ស្ត្រីដែលមានប្រវត្តិកូនក្រៅស្បូន
- ស្ត្រីដែលមានការឈឺពេលមានរដូវ



# តើគ្រូពេទ្យត្រូវពិនិត្យអ្វីខ្លះ មុនលេបថ្នាំគ្រាប់ ស៊ីអូស៊ី ?
## (សម្រាប់អ្នកទទួលសេវាក្នុងគ្លីនិក

គ្រូពេទ្យនឹងសាកសួរអំពីព័ត៌មានទូទៅរបស់ស្ត្រី ដូចជាប្រវត្តិជំងឺ ប្រវត្តិរដូវ ការប្រើថ្នាំផ្សេងៗ។ល។ បន្ថែមពីនេះ ក៏មានការពិនិត្យសុខភាព ដើម្បីធានាថាស្ត្រីអាចលេបថ្នាំបានដោយសុវត្ថិភាព ។



# តើពេលណាដែលស្ត្រីអាចលេបថ្នាំគ្រាប់ ស៊ីអូស៊ី បាន ?

ជាទូទៅ ស្ត្រីអាចលេបថ្នាំបាន ៖

- នៅថ្ងៃចន្លោះមានរដូវចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៥ ។
- ក្រោយសម្រាលភ្លាម បើមិនបំបៅដោះកូន ។
- បន្ទាប់ពី៦ខែក្រោយក្រោយសម្រាលដោយបំបៅដោះកូន ។ ប៉ុន្តែបើមិនបំបៅដោះកូនទេ អាចលេបបានបន្ទាប់ពីសម្រាលកូនបាន៦សប្តាហ៍ ។
- ក្នុងអំឡុងពេល៧ថ្ងៃក្រោយរលូត ឬរំលូតដោយគ្មានការករោគ។



# តើស្ត្រីត្រូវលេបថ្នាំយ៉ាងដូចម្តេចខ្លះ ?

ត្រូវលេបតាមសញ្ញាព្រួញដំបូង មួយថ្ងៃមួយគ្រាប់ឲ្យទៀងពេល ហើយលេបរហូតទាល់តែអស់ថ្នាំពីបន្ទះ ទោះជាកំពុងមានរដូវក៏ដោយ។ នៅពេលអស់ថ្នាំហើយ សូមបន្តលេបបន្ទះថ្មីទៀត ។



## តើស្ត្រីត្រូវធ្វើយ៉ាងណា បើភ្លេចលេបថ្នាំគ្រាប់ ស៊ីអូស៊ី ?

- បើស្ត្រីភ្លេចលេបថ្នាំគ្រាប់ពណ៌លឿង១គ្រាប់ ឬ២គ្រាប់: ត្រូវលេប១គ្រាប់ ឬ២គ្រាប់ ភ្លាមពេលនឹកឃើញហើយ បន្តលេបថ្នាំតាមពេលដែលធ្លាប់លេបធម្មតាវិញ ។
- បើស្ត្រីភ្លេចលេបថ្នាំគ្រាប់ពណ៌លឿង៣គ្រាប់ ឡើងទៅ: បើគាត់បានរួមភេទ ស្ត្រីត្រូវលេបថ្នាំការពារកំណើតបន្ទាប់ ហើយបន្តការលេបថ្នាំតាមពេលធ្លាប់លេបវិញ រហូតដល់អស់ថ្នាំពីបន្ទះ និងប្រើស្រោមអនាម័យក្នុងពេលរួមភេទ ឬតមមិនរួមភេទរយៈពេល៧ថ្ងៃ ។
- បើស្ត្រីភ្លេចលេបថ្នាំគ្រាប់ពណ៌ត្នោត : ត្រូវចោលថ្នាំដែលភ្លេចនោះ ហើយបន្តលេបថ្នាំក្នុងបន្ទះថ្មីទៀត ។

**សំគាល់**

ចំពោះស្ត្រីដែលភ្លេចលេបថ្នាំញឹកញាប់ គួរជ្រើសរើសមធ្យោបាយពន្យារកំណើតផ្សេងវិញ ។

## តើផលរំខានអ្វីខ្លះអាចកើតមានក្រោយពីលេបថ្នាំគ្រាប់ ស៊ីអូស៊ី ?

ស្ត្រីភាគច្រើន ប្រើថ្នាំលេបនេះមិនមានផលរំខានទេ។



ប៉ុន្តែស្ត្រីខ្លះមានផលរំខានដូចជា :

- ដោះឡើងតឹង ឬឈឺដោះ
- ឈឺក្បាលតិចតួច វិលមុខ ចង្អោរតិចតួច
- អាចប្រែប្រួលទម្ងន់
- អាចមានអារម្មណ៍ដូចចាញ់កូន

ផលរំខានទាំងនេះនឹងបាត់ទៅវិញបន្ទាប់ពីលេបថ្នាំបាន ៣ឬ៤បន្ទះ។

## តើពេលណាស្ត្រីត្រូវត្រឡប់មកកាន់គ្លីនិកវិញ ?

**១- ពេលមានសញ្ញាដូចខាងក្រោមនេះ**

- ភ្នែក ឬស្បែកឡើងលឿង
- ឈឺពោះផ្នែកខាងក្រោមខ្លាំង
- ឈឺក្បាលខ្លាំង
- ស្រវាំងភ្នែក
- ឈឺទ្រូង ហើយពិបាកដកដង្ហើម ។
- ឈឺជើងខ្លាំង

**២- ពេលណាត់ជួបគ្រូពេទ្យដើម្បីតាមដានសុខភាព និងទទួលថ្នាំបន្ត**

ស្ត្រីត្រូវទៅពិនិត្យសុខភាព១ឆ្នាំម្តង តាមពេលណាត់របស់ពេទ្យ ។

**៣- ពេលចង់ឈប់ប្រើថ្នាំលេប ឬចង់ប្តូរមធ្យោបាយពន្យារកំណើត ឬពេលមានចម្ងល់ ដោយសារពាក្យចចាមអារាមមិនល្អ ទាក់ទងនឹងថ្នាំលេប**

ស្ត្រីអាចបញ្ឈប់ ឬប្តូរមធ្យោបាយផ្សេងៗទៀត នៅគ្រប់ពេលដែលនាងចង់ ។



# ២ ~ ថ្នាំគ្រាប់ ភីអូភី

## តើថ្នាំគ្រាប់ ភីអូភី ការពារកំណើតដោយរបៀបដូចម្ដេច ?

ជាធម្មតា ការបង្កកំណើតទារកក្នុងផ្ទៃ កើតឡើងដោយការភពប្រសព្វរវាងមេជីវិតឈ្មោល(ដែលមានក្នុងទឹកកាមបុរស ជាមួយនឹងមេជីវិតញី (ដែលបញ្ចេញដោយកន្សោមពងស្ត្រី ។

បន្ទាប់ពីលេបថ្នាំនេះ ជាតិអ័រម៉ូនបានសាយភាយបន្តិចម្ដងៗ ចូលក្នុងរាងកាយរបស់ស្ត្រី ធ្វើឲ្យទឹករំអិលមាត់ស្បូនឡើងខាប់ អាចរារាំងការជ្រៀតចូលនៃមេជីវិតឈ្មោលទៅក្នុងស្បូន ។

បន្ថែមពីលើនេះ ជាតិអ័រម៉ូន ក៏បានបញ្ឈប់ការខ្វាក់មេជីវិតញី និងធ្វើឲ្យស្រទាប់ក្នុងរបស់ស្បូនប្រែប្រួល ធ្វើឲ្យការបង្កកំណើត ត្រូវបានការពារ ។



## តើលេបថ្នាំគ្រាប់ ភីអូភី មានប្រសិទ្ធិភាពដូចម្តេចខ្លះ ?

លេបថ្នាំគ្រាប់ ភីអូភី ១បន្ទះ អាចការពារការមានផ្ទៃពោះបានរយៈពេល ១ខែ ប្រសិនបើស្ត្រីលេបថ្នាំបានត្រឹមត្រូវ និង ទៀងទាត់ ។ ថ្នាំគ្រាប់ ភីអូភី មានប្រសិទ្ធិភាព ៩៩.៥ ភាគរយ ។



**សំគាល់**

ការប្រើថ្នាំលេបពន្យារកំណើត ភីអូភី មិនអាចការពារ ជំងឺកាមរោគ និង ជំងឺអេដស៍ បានទេ ។

## តើថ្នាំគ្រាប់ ភីអូភី ផ្តល់ប្រយោជន៍ដូចម្តេចខ្លះ ?

មានប្រសិទ្ធិភាពខ្ពស់ និងសមស្របចំពោះស្ត្រីដែលបំបៅដោះកូន ដែលមានអាយុតិចជាង៦ខែ ដោយមិនបន្ថយបរិមាណទឹកដោះឡើយ ។ ពេលឈប់លេបថ្នាំ ភីអូភី ស្ត្រីនឹងមានកូនវិញ យ៉ាងឆាប់រហ័ស ។



**សំគាល់**

ការប្រើថ្នាំលេបពន្យារកំណើត ភីអូភី មិនអាចការពារជំងឺកាមរោគ និងជំងឺអេដស៍បានទេ

# តើស្ត្រីណាខ្លះដែលអាចលេបថ្នាំគ្រាប់ ភីអូភី បាន ?

- ស្ត្រីត្រូវការមធ្យោបាយពន្យារកំណើតដែលមានប្រសិទ្ធិភាពខ្ពស់
- ស្ត្រីកំពុងបំបៅដោះកូនដែលមានអាយុតិចជាង៦ខែ
- ស្ត្រីមានការចងចាំការលេបថ្នាំបានល្អ
- ស្ត្រីមិនទាន់មានកូន និងមិនអាចប្រើថ្នាំគ្រាប់ ស៊ីអូស៊ីបាន
- ស្ត្រីមិនទាន់រៀបការ
- ស្ត្រីទើបនឹងរលូត ឬរំលូតកូន
- ស្ត្រីមានផ្ទុកមេរោគអេដស៍



# តើគ្រូពេទ្យត្រូវពិនិត្យអ្វីខ្លះ មុននឹងលេបថ្នាំគ្រាប់ ភីអូភី ?
## (សម្រាប់អ្នកទទួលសេវាក្នុងគ្លីនិក

គ្រូពេទ្យនឹងសាកសួរអំពីព័ត៌មានទូទៅរបស់ស្ត្រីដូចជា ប្រវត្តិជំងឺ ប្រវត្តិរដូវ ការប្រើថ្នាំផ្សេងៗ។ល។ បន្ថែមពីនេះ ក៏មានការពិនិត្យសុខភាព ដើម្បីធានាថាស្ត្រីអាចលេបថ្នាំ បានដោយសុវត្ថិភាព ។



## តើពេលណាដែលស្ត្រីអាចលេបថ្នាំគ្រាប់ ភីអូភី បាន ?

ស្ត្រីអាចលេបថ្នាំគ្រាប់ ភីអូភី បានគ្រប់ពេលទាំងអស់ ឲ្យតែប្រាកដថាគ្មានផ្ទៃពោះ ។

ជាទូទៅស្ត្រីអាចលេបថ្នាំបាន :

- ចាប់ពីថ្ងៃមានរដូវរហូតដល់ថ្ងៃទី៥
- បន្ទាប់ពីសម្រាលកូនភ្លាម បើមិនបំបៅដោះកូន
- បើស្ត្រីបំបៅដោះកូន ត្រូវលេបថ្នាំក្រោយសម្រាល ៦សប្តាហ៍ ហើយលេបរហូតដល់៦ខែ ទើបប្តូរមកលេបថ្នាំគ្រាប់ស៊ីអូស៊ីវិញ
- ក្នុងអំឡុងពេល ៧ថ្ងៃក្រោយរលូត ឬរំលូតដោយគ្មានការករោគ

## តើស្ត្រីត្រូវលេបថ្នាំគ្រាប់ ភីអូភី យ៉ាងដូចម្តេច ?

ត្រូវលេបតាមសញ្ញាព្រួញដំបូង មួយថ្ងៃ១គ្រាប់ ឲ្យទៀងម៉ោង ហើយលេបរហូតទាល់តែអស់ថ្នាំពីបន្ទះ ទោះជាកំពុងមាន រដូវក៏ដោយ ។ នៅពេលអស់ថ្នាំហើយ សូមបន្តលេបបន្ទះថ្មី នៅថ្ងៃបន្ទាប់ ។



## បើភ្លេចលេបថ្នាំគ្រាប់ពន្យារកំណើត ភីអូភី ត្រូវធ្វើដូចម្ដេច ?

បើភ្លេចលេប ១គ្រាប់ លើសពី ៣ម៉ោង ស្ត្រីគួរតែ :

- លេប១គ្រាប់ភ្លាម ពេលនឹកឃើញ ។
- បន្តលេបថ្នាំដែលនៅសល់ក្នុងបន្ទះដូចធម្មតារហូតអស់ ពីបន្ទះ។ ប្រើស្រោមអនាម័យ ក្នុងពេលរួមភេទ ឬតមរួមភេទរយៈពេល២ថ្ងៃ ។



បើនាងបានរួមរ័ក្សក្នុងចន្លោះពេលដែលភ្លេចលេបថ្នាំ នាងត្រូវទៅជួបជាមួយគ្រូពេទ្យ ដើម្បីពិភាក្សាពីការ ការពារកំណើតបន្ទាន់ ។

## តើផលរំខានអ្វីខ្លះអាចកើតមាន ក្រោយពីលេបថ្នាំ ភីអូភី ?

ស្ត្រីភាគច្រើន លេបថ្នាំនេះមិនមានផលរំខានទេ ប៉ុន្តែស្ត្រីខ្លះ មានផលរំខានដូចជា :

- អាចឈឺក្បាលពោះ
- អាចបាត់រដូវមួយរយៈ
- អាចប្រែប្រួលទម្ងន់
- អាចធ្លាក់ឈាមមិនទៀងទាត់តាមទ្វារមាស
- អាចឈឺដោះ ឬដោះឡើងតឹង



ផលរំខានទាំងនេះមិនមែនជាសញ្ញានៃជំងឺទេ ហើយក៏មិនធ្ងន់ធ្ងរ ឬបណ្តាលឲ្យប៉ះពាល់ដល់សុខភាពរបស់ស្ត្រីដែរ ។ ផលរំខានទាំងនេះនឹងបាត់ទៅវិញនៅរយៈពេលក្រោយ ។

## តើពេលណា ស្ត្រីត្រូវត្រឡប់មកកាន់គ្លីនិកវិញ ?

- បាត់រដូវបន្ទាប់បីមានរដូវទៀងទាត់រយៈពេលយូរមកហើយ
- ធ្លាក់ឈាមរដូវច្រើនខុសធម្មតា
- ផ្អែក ឬស្បែកឡើងលឿង
- ឈឺពោះផ្នែកខាងក្រោមខ្លាំង
- ឈឺក្បាលខ្លាំង ឬស្រវាំងភ្នែក

ស្ត្រីត្រូវមកជួបគ្រូពេទ្យ ដើម្បីពិនិត្យសុខភាពរយៈពេល១ឆ្នាំម្តង ទោះបីជាគ្មានរោគសញ្ញាអ្វីក៏ដោយ ។



បើមានចម្ងល់ ដោយសារពាក្យចចាមអារាមមិនល្អ ដែលទាក់ទងនឹងថ្នាំលេប ភីអូភី សូមស្ត្រីទៅជួបគ្រូពេទ្យដើម្បីពិភាក្សា ។

# ថ្នាំគ្រាប់ការពារកំណើតបន្ទាន់

គឺជាថ្នាំគ្រាប់ដែលគេប្រើភ្លាមៗ (ក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពីមានការរួមភេទដោយមិនបានការពារ ។




*គុណសម្បត្តិ :*

មានប្រសិទ្ធិភាពខ្ពស់ ប្រសិនបើប្រើក្នុងអំឡុងពេល៧២ម៉ោង ក្រោយការរួមភេទដែលមិនបានការពារ ។

*គុណវិបត្តិ :*

- ស្ត្រីអាចប្រើបានតែម្តងគត់ក្នុងករណីចាំបាច់ និងបន្ទាន់ បន្ទាប់មកស្ត្រីត្រូវប្រើមធ្យោបាយពន្យារកំណើតផ្សេងទៀត ដើម្បីការពារការមានផ្ទៃពោះ ។
- មិនអាចប្រើជាមធ្យោបាយពន្យារកំណើតជាប្រចាំបានទេ ។
- មិនអាចប្រើដើម្បីការពារការមានផ្ទៃពោះបានទេ ប្រសិនបើមានការរួមភេទដោយមិនបានការពារលើសពី៧២ ម៉ោង ។
- មានផលរំខាន ដូច ថ្នាំគ្រាប់ស៊ីអូស៊ី និងភីអូភីផងដែរ ។

*របៀបប្រើ :*

ថ្នាំនេះអាចប្រើបានចំពោះស្ត្រីគ្រប់រូប បន្ទាប់ពីធ្វើការពិគ្រោះជាមួយគ្រូពេទ្យ ។

## សេវានៅគ្លីនិក "រ៉ាក់"

១- ពន្យារកំណើត (ថ្នាំលេប ថ្នាំចាក់ កងដាក់ដៃ កងដាក់ក្នុងស្បូន ស្រោមអនាម័យ បញ្ឈប់កំណើតរហូត (ចងដៃស្បូន និងចងបំពង់មេជីវិតបុរស

២- ពិនិត្យ និងព្យាបាលជំងឺទូទៅ (មនុស្សចាស់-កុមារ

៣- ថែទាំផ្ទៃពោះមុនសម្រាលនិងសុខភាពក្រោយសម្រាល

៤- ពិនិត្យ និងព្យាបាលជំងឺកាមរោគ (បុរស-ស្ត្រី

៥- វិភាគកោសិកាមាត់ស្បូនរកមើលជំងឺមហារីកមាត់ស្បូន

៦- ព្យាបាលដុតមាត់ស្បូនដោយឧបករណ៍ទំនើប

៧- ពិនិត្យ និងព្យាបាលសុខភាពបន្តពូជស្ត្រី និងបុរស

៨- សេវាថែទាំ និងគាំទ្រស្ត្រីត្រូវគេរំលោភ

៩- មន្ទីរពិសោធន៍វេជ្ជសាស្ត្រ

១០- ផ្តល់ប្រឹក្សា និងពិនិត្យឈាមរកមេរោគអេដស៍

១១- ផ្តល់ប្រឹក្សាអំពីសុខភាពបន្តពូជបុរស-ស្ត្រីមុនរៀបការ

១២- ព្យាបាល និងថែទាំក្រោយរលូតកូន

១៣- ព្យាបាល និងផ្តល់ប្រឹក្សាការមិនមានកូន

១៤- វះកាត់តូច

១៥- ចាក់ថ្នាំការពារតេតាណូស ថ្លើមប្រភេទវីរុសបេ និង វ៉ាក់សាំងការពារមហារីកមាត់ស្បូន

១៦- ពិនិត្យអេកូសាស្ត្រ

# សិទ្ធិរបស់អតិថិជនដែលមកទទួលសេវា នៅគ្លីនិក "រ៉ាក់" មានដូចខាងក្រោម :

១- *សិទ្ធិក្នុងការទទួលយកព័ត៌មាន :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលយកព័ត៌មានស្តីអំពីផលប្រយោជន៍នៃការពន្យារកំណើត ទីកន្លែងផ្តល់សេវាពន្យារកំណើត និងសេវាថែទាំសុខភាពផ្លូវភេទ ។

២- *សិទ្ធិក្នុងការទទួលសេវា :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាពន្យារកំណើតដោយមិនគិតអំពីស្ថានភាពសង្គម សេដ្ឋកិច្ច សាសនា និន្នាការ នយោបាយ ជនជាតិ ពណ៌សម្បុរ ស្ថានភាពអាពាហ៍ពិពាហ៍ ឬទីកន្លែងស្នាក់នៅឡើយ ។

៣- *សិទ្ធិក្នុងការជ្រើសរើស :* អតិថិជនទាំងអស់មានសិទ្ធិសម្រេចចិត្តក្នុងការជ្រើសរើសប្រើប្រាស់ ឬមិនប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយដោយសេរី ។

៤- *សិទ្ធិមានសុវត្ថិភាព :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលបាននូវសុវត្ថិភាព សុខភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្តក្នុងការប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយ ។

៥- *សិទ្ធិឯកជន :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការពិភាក្សាតម្រូវការ ការព្រួយបារម្ភ ឬការពិនិត្យរាងកាយរបស់ពួកគេ នៅក្នុងទីកន្លែងណាដែលគេមានអារម្មណ៍កក់ក្តៅ ។

៦- *សិទ្ធិរក្សាការសម្ងាត់ :* អតិថិជនទាំងអស់គួរតែត្រូវបានធានាថារាល់ព័ត៌មានទាំងឡាយដែលគេបានប្រាប់ ឬសេវាទាំងឡាយដែលគេបានទទួលនឹងមិនត្រូវបន្តទៅអ្នកទីពទេ លើកលែងតែមាន ការយល់ព្រមពីសាម៉ីខ្លួន ។

៧- *សិទ្ធិរក្សាភាពថ្លៃថ្នូរ និងកិត្តិយស :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលរាក់ទាក់ដោយភាពគួរសម ការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន និងការគោរពដោយភាពថ្លៃថ្នូរ ដោយមិនប្រកាន់នូវចំណេះដឹង ស្ថានភាពសង្គម ឬឋានន្តរសក្តិឡើយ ។

៨- *សិទ្ធិមានផាសុកភាព :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្មដែលមានលក្ខណៈផាសុកភាពដោយអារម្មណ៍ពេញចិត្តពេញថ្លើម ។

៩- *សិទ្ធិក្នុងការបន្ត :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការទទួលសេវាកម្ម និងមធ្យោបាយពន្យារកំណើតបានយូរទៅតាមសេចក្តីត្រូវការរបស់ពួកគេ ។

១០- *សិទ្ធិក្នុងការបញ្ចេញមតិយោបល់ :* អតិថិជនទាំងអស់មានសិទ្ធិក្នុងការបញ្ចេញយោបល់ និងទស្សនៈ អំពីការផ្តល់សេវាកម្មដែលពួកគេបានទទួល ។

# RHAC អាសយដ្ឋានគ្លីនិក "រ៉ាក់"

## រាជធានីភ្នំពេញ

**គ្លីនិកភ្នំពេញ១ :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៦ ផ្លូវលេខ១៥០ ស.វាលវង់
ខណ្ឌ៧មករា ទូរស័ព្ទ : ០២៣-៨៨១ ៦២១

**គ្លីនិកភ្នំពេញ២ :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៣៨-៤០ ផ្លូវលេខ៤៣២ ស.ទួលទំពូង១
ខណ្ឌចំការមន ទូរស័ព្ទ : ០២៣-២១៨ ៥០៤

**គ្លីនិកស្ទឹងមានជ័យ :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ ១៩. ២០. ២១ ភូមិត្រពាំងថ្លឹង
ស.ចោមចៅ ខណ្ឌដង្កោ
ទូរស័ព្ទ : ០២៣-៩៨៥ ៧៧៣

**គ្លីនិកចាក់អង្រែក្រោម :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ ១៦០៧ ភូមិទួលរកា
ស.ចាក់អង្រែក្រោម ខណ្ឌមានជ័យ
ទូរស័ព្ទ : ០២៤-៩៨៥ ០៧៩

**គ្លីនិកទួលសង្កែ / មណ្ឌលយុវវ័យ:** ( មានសេវាពិនិត្យMSM)
ផ្ទះលេខ ១៦២៤ ផ្លូវជាតិលេខ៥ ភូមិឃ្លាំងសាំង
ក្រុម៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ
ទូរស័ព្ទ :០២៣-៩៩០ ៧៧៣

**គ្លីនិកទឹកថ្លា :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខG35-G37 ផ្លូវហ្គដឌី
សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ
ទូរស័ព្ទ : ០២៣-៨៨៣ ០២៦

**គ្លីនិកទំនប់ថ្មី :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៣A+៤A ផ្លូវមុន្នីរ៉េត
ភូមិដំណាក់ធំ១ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ទូរស័ព្ទ : ០២៣-៩៩៥ ៤៧៦

## ខេត្តបាត់ដំបង

**គ្លីនិក :** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ១៩៤,៤៤៩ ភូមិព្រែកមហាទេព
ឃុំស្វាយប៉ោ ស្រុកបាត់ដំបង
ទូរស័ព្ទ : ០៥៣-៩៥២ ៦១០

## ខេត្តព្រះសីហនុ

**គ្លីនិក / មណ្ឌលយុវវ័យ:** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ៥៩៥ ផ្លូវឯករាជ្យ មណ្ឌល៤ សង្កាត់៤
ខណ្ឌមិត្តភាព ទូរស័ព្ទ : ០៣៤-៩៣៣ ៩៤២

## ខេត្តកំពង់ចាម

**គ្លីនិក / មណ្ឌលយុវវ័យ:** ( មានសេវាពិនិត្យ MSM )
ផ្ទះលេខ១០ ផ្លូវត្រសក់ផ្អែម ភូមិ១៥ ឃុំកំពង់ចាម
ស្រុកកំពង់ចាម ទូរស័ព្ទ : ០៤២-៩៤១ ៥០២

**គ្លីនិកសួង :** ( មានសេវាពិនិត្យ MSM )
ភូមិសួងលិច ឃុំសួង ស្រុកត្បូងឃ្មុំ
ទូរស័ព្ទ : ០១៦-៣០៦ ៥១១

## ខេត្តតាកែវ

**គ្លីនិក :** ផ្ទះលេខ៥ ផ្លូវលេខ៨ ភូមិឡូរី
សង្កាត់រការក្នុង ក្រុងដូនកែវ
ទូរស័ព្ទ : ០៣២-៩៣១ ៣៦១

## ខេត្តសៀមរាប

**គ្លីនិក / មណ្ឌលយុវវ័យ :** ( មានសេវាពិនិត្យ MSM )
ភូមិត្រពាំងសេះ ឃុំគោកចក
ទូរស័ព្ទ : ០៦៣-៩៦៤ ៩៦០

## ខេត្តកំពង់ស្ពឺ

**គ្លីនិក / មណ្ឌលយុវវ័យ :** ( មានសេវាពិនិត្យ MSM )
ភូមិស្ពោនទី១ សង្កាត់រកាធំ ក្រុងច្បារមន
ខេត្តកំពង់ស្ពឺ ទូរស័ព្ទ :០២៥-៩៨៧ ១៤៥

## ខេត្តស្វាយរៀង

**គ្លីនិក :** ៥០ ភូមិបាវិតកណ្តាល សង្កាត់បាវិត
ក្រុងបាវិត ទូរស័ព្ទ : ០៤៤-៩៤៦ ០៦៦

## ខេត្តកំពត

**គ្លីនិក :** ផ្ទះលេខ៥១ ផ្លូវជាតិលេខ៣៣
ភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត
ទូរស័ព្ទ : ០៣៣ ៩៣២ ៧៦៨

សៀវភៅនេះផលិតតាមបច្ចេកទេស និងគំនិតរបស់បុគ្គលិក
អង្គការ " រ៉ាក់ " ក្រោមការឧបត្ថម្ភថវិការបស់
ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ USAID
ក្រោមគម្រោងរួមគ្នាដើម្បីសុខភាពល្អ

<u>កំណត់សម្គាល់</u>: តួអង្គនៅក្នុងសៀវភៅ គ្រាន់តែជាការសម្តែងប៉ុណ្ណោះ

បោះពុម្ពលើកទី.... ចំនួន ............... ក្បាល ឆ្នាំ២០១២

**IEC,2012**